ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

**អង្គភាពគាំពារជនរងគ្រោះ**
**Victims Support Section**
**Section d'appui aux victimes**

ភ្នំពេញ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១១

# សេចក្តីប្រកាសព័ត៌មាន

# វេទិកាថ្នាក់តំបន់លើកទី៨សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០២

អង្គភាពគាំពារជនរងគ្រោះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នឹងរៀបចំវេទិកាថ្នាក់តំបន់លើកទី៨ នៅខេត្តកំពង់ចាម សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ដែលទើបទទួលស្គាល់ថ្មីៗនេះ នៃសំណុំរឿង០០២ ចំនួន ៤៥០ នាក់ មកពីខេត្តកំពង់ចាម ខេត្តរតនគីរី ខេត្តមណ្ឌលគីរី ខេត្តស្ទឹងត្រែង ខេត្តក្រចេះ ខេត្តស្វាយរៀង និងខេត្តព្រៃវែង វេទិកាថ្នាក់តំបន់លើកនេះ នឹងប្រព្រឹត្តទៅនៅ ***សណ្ឋាគារ និងភោជនីយដ្ឋានភ្នំប្រុស នាថ្ងៃព្រហស្បតិ៍ ទី១៥ ខែកញ្ញា ឆ្នាំ២០១១ វេលាម៉ោង៧:៣០ ព្រឹក ដល់ ម៉ោង ៣:៣០ រសៀល*** *(អត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋប្បវេណី នឹងត្រូវបានរក្សាជាសម្ងាត់)* ។

ដើមបណ្តឹងរដ្ឋប្បវេណីទាំង ៤៥០នាក់ ដែលនឹងចូលរួមវេទិកាថ្នាក់តំបន់លើកនេះ ស្ថិតក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០២ ដែលត្រូវបានអង្គបុរេជំនុំជម្រះ ទទួលស្គាល់ចំនួន ១.៧៤៥ នាក់ កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០១១ នេះ និងពេលក្រោយមកទៀត។ រហូតមកទល់ពេលនេះ ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២ សរុបទាំងអស់ មានចំនួន ៣.៨៦៧ នាក់។

វេទិកាថ្នាក់តំបន់នេះគឺជាសកម្មភាពដ៏សំខាន់មួយក្នុងចំណោមសកម្មភាពនានារបស់ អង្គភាពគាំពារជនរងគ្រោះ ក្នុងការលើកកម្ពស់ការចូលរួមរបស់ជនរងគ្រោះឲ្យកាន់តែទូលំទូលាយក្នុងដំណើរការរបស់ អ.វ.ត.ក ក្នុងឆ្នាំ ២០១១ និងដើម្បីពង្រឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងដំណើរការច្បាប់សម្រាប់សំណុំរឿង០០២។ វេទិកាថ្នាក់តំបន់ នេះមានគោលបំណងផ្តល់ឱកាសឲ្យដើមបណ្តឹងរដ្ឋប្បវេណី ៖

- ជួបជាមួយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដើម្បីពិភាក្សាអំពីសិទ្ធិក្នុងការដាក់ពាក្យបណ្តឹង នីតិវិធីចូលរួមនៅក្នុងដំណើរការកាត់ក្តី ក៏ដូចជាប្រមូលគំនិតដែលពាក់ព័ន្ធនឹងសំណងដែលស្នើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីរៀបចំគម្រោងសំណងនិងស្នើទៅកាន់ អ.វ.ត.ក ។
- ជួបជាមួយមន្ត្រីមកពីការិយាល័យនានានៃ អ.វ.ត.ក និងតំណាងសង្គមស៊ីវិល ដើម្បីស្វែងយល់ពីការវិវឌ្ឍថ្មីៗរបស់តុលាការ។
- ដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០១ ដើម្បីចែករំលែកបទពិសោធសម្រាប់សំណុំរឿង០០២។

ចាប់ពីឆ្នាំ២០០៩ ដល់ខែកក្កដាឆ្នាំ២០១១នេះ អង្គភាពគាំពារជនរងគ្រោះបានរៀបចំដោយជោគជ័យនូវវេទិកាថ្នាក់តំបន់ច្រើនលើករួចមកហើយ ដោយមានការចូលរួមពីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣,៦៧៨ នាក់ មកពី ២៤ ខេត្ត រាជធានី នៃព្រះរាជាណាចក្រកម្ពុជា។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖
**អ៊ុម សុភា**
ប្រធានកម្មវិធីផ្សព្វផ្សាយនៃអង្គភាពគាំពារជនរងគ្រោះ
ទូរស័ព្ទចល័ត: ០៧៧ ៧៧៧ ៣៦៧
អ៊ីម៉ែល: im.sophea@eccc.gov.kh